**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**

# សេចក្តីជូនដំណឹង
## ស្តីពី
## ពិធីបុណ្យកឋិនទាន ដង្ហែនៅកាន់វត្តក្តីកណ្តាល ក្រុងព្រៃវែង

ក្រសួងមុខងារសាធារណៈសូមជម្រាបជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់មេត្តាជ្រាបថា ដើម្បីចូលរួមថែរក្សា និងលើកស្ទួយវប្បធម៌ ប្រពៃណីព្រះពុទ្ធសាសនា ក្រសួងមុខងារសាធារណៈនឹងដង្ហែអង្គកឋិនទានទៅកាន់វត្តក្តីកណ្តាលស្ថិតនៅភូមិ៥ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង។

អាស្រ័យដូចបានជម្រាបជូនខាងលើ ក្រសួងមុខងារសាធារណៈ សូមអំពាវនាវដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំ មន្ត្រីរាជការ និងសប្បុរសជនទាំងអស់ មេត្តាចូលរួមឱ្យបានអធិកអធម និងចាប់មគ្គផលតាមកម្លាំងសទ្ធាជ្រះថ្លារៀងៗខ្លួន។

**កម្មវិធីបុណ្យ**

- ថ្ងៃសុក្រ ១១រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២ ម៉ោង៣:០០នាទីរសៀល ជួបជុំពុទ្ធបរិស័ទ ធ្វើបទនមស្សការ សមាទានសីល និងនិមន្តព្រះសង្ឃចម្រើនព្រះបរិត្ត និងធ្វើបដិសណ្ឋារកិច្ចភ្ញៀវកិត្តិយស នៅទីស្តីការក្រសួងមុខងារសាធារណៈ។
- ថ្ងៃសៅរ៍ ១២រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២២ ខែតុលា ឆ្នាំ២០២២ ម៉ោង៦:០០នាទីព្រឹក ជួបជុំពុទ្ធបរិស័ទដង្ហែអង្គកឋិនទានពីក្រសួងមុខងារសាធារណៈ ឆ្ពោះទៅកាន់វត្តក្តីកណ្តាល ដើម្បីវេរប្រគេនព្រះសង្ឃជាកិច្ចបង្ហើយបុណ្យ។

**សម្រាប់ការចូលរួមចាប់មគ្គផល៖** សូមផ្ទេរទៅគណនីABA Account No: 077987989 USD / 081987989 KHR Name: CHAN VANNA ឬចូលរួមចាប់មគ្គផលនៅនាយកដ្ឋានហិរញ្ញវត្ថុនិងផ្គត់ផ្គង់ នៃក្រសួងមុខងារសាធារណៈ។

**ព័ត៌មានបន្ថែម សូមទាក់ទង៖**

| | |
|---|---|
| ១. ឯកឧត្តម ហង្ស ផាំផាន | ទូរស័ព្ទលេខ ០១១ ៨១២ ៧០៥ |
| ២. លោក ចាន់ វណ្ណា | ទូរស័ព្ទលេខ ០៧៧ ៩៨៧ ៩៨៩ ឬ ០៩៦ ៩៩៩៩ ៣២០ |
| ៣. លោក សោម សាវេត | ទូរស័ព្ទលេខ ០១៥ ២១៤ ៤៤៤ ឬ ០១៧ ៤៩៤ ៣៤៣។ |

សូមប្រសិទ្ធពរបវរសួស្តីជូន ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ ជួបប្រទះតែនឹងសេចក្តីសុខ និងសេចក្តីចម្រើនគ្រប់ប្រការ ពិសេសគឺរៀចាកផុតពីជំងឺកូវីដ-១៩ ព្រមទាំងសមប្រកបនឹងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ៕

ថ្ងៃ សុក្រ ១២កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែតុលា ឆ្នាំ២០២២